ហត្ថាកសិករ លីមីតធីត
HATTHA KAKSEKAR LIMITED

# របាយការណ៍ត្រីមាសទី១

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០

**Subsidiary of krungsri bank**
A member of MUFG, a global financial group

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ឆ្នាំ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៥ ០៧៦ ៤៨៧ | ៤ ៩៩៩ ៣២៣ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៤ ០៩៧ ៤៣២ | ៤ ១៩១ ០០៦ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ៩៧៩ ០៥៥ | ៨០៨ ៣១៧ | ៦៦៧ ៩៧០ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី១ឆ្នាំ២០២០** | **ត្រីមាសទី១ឆ្នាំ ២០១៩** | **ត្រីមាសទី១ឆ្នាំ ២០១៨** |
| ចំណូលសរុប (លានរៀល) | ១៧៩ ៥៩៥ | ១៣២ ៧៨៧ | ១០៥ ១៧៨ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៣៥ ៥៣២ | ៣០ ៩៩២ | ២០ ៣១២ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ២៨ ២២០ | ២៤ ០៩៩ | ១៦ ១៦៨ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ១២ ៩៥២ | ២៣ ៩៤១ | ១៤ ២៦៥ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី១ឆ្នាំ២០២០** | **២០១៩** | **២០១៨** |
| អនុបាតសាធនភាព (ភាគរយ) | ២០,៤៤ | ១៩,៤ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤១៩ | ៥១៨ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១១៦,៦ | ១១៣,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ០,៣១ | ០,៣០ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥០,៦ | ៥៧,០ | ៦៣,៤ |
| | **ត្រីមាសទី១ឆ្នាំ២០២០** | **ត្រីមាសទី១ឆ្នាំ២០១៩** | **ត្រីមាសទី១ឆ្នាំ ២០១៨** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ០,៥៦ | ០,៦១ | ០,៤៦ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ២,៨៨ | ៣,៤៦ | ៣,៣៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៥១ | ១៥៧ | ១៤៩ |

[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



អ្នកស្រី Voranuch DEJAKAISAYA
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡុញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ ២០១៩ យើងសម្រេចបាននូវលទ្ធផលយ៉ាងគាប់ប្រសើរ លើសពីការរំពឹងទុកស្ទើរតែគ្រប់ផ្នែក។ ហើយសម្រាប់ឆ្នាំនេះយើងនៅតែបន្តការផ្តល់ជូននូវសេវាហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ថាជាស្ថាប័នឈានមុខគេនៅកម្ពុជា ជាពិសេសក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់យើងក្នុងការត្រៀមខ្លួនក្លាយជា ធនាគារពាណិជ្ជ នាពេលដ៏ខ្លីខាងមុខ ដើម្បីផ្តល់ជូននូវការផ្លាស់ប្រែជាវិជ្ជមានកាន់តែច្រើន។

ជាអកុសល ការរីករាលដាលជម្ងឺកូវីដ ១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏ដូចជានៅលើពិភពលោកយ៉ាងខ្លាំង។ ហើយការរីករាលដាលនៅតែកំពុងបន្តទៀត ដែលតាមរយៈនេះបានបង្ខំឱ្យអាជីវកម្មជាច្រើនរួមទាំង ហត្ថាកសិករ លីមីតធីត ផងដែរ ចាំបាច់ត្រូវពិនិត្យឡើងវិញនូវផែនការអាជីវកម្ម និងដាក់ចេញនូវសកម្មភាពចាំបាច់បន្ទាន់ ជាច្រើនដើម្បីធានាថានិយោជិត និងអតិថិជនរបស់យើងមានសុវត្ថិភាពជាមួយនឹងការរក្សាឱ្យបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម។

គណៈគ្រប់គ្រងបានអនុវត្តវិធានការណ៍ការពារយ៉ាងសកម្មដើម្បីការពារនូវសុខសុវត្ថិភាពដល់និយោជិត និងអតិថិជនទាំងអស់ដែលបានអញ្ជើញមកប្រើប្រាស់សេវារបស់ ហត្ថាកសិករ លីមីតធីតនៅការិយាល័យដោយផ្ទាល់។ សាច់ប្រាក់ងាយស្រួលត្រូវបានពិនិត្យយ៉ាងហ្មត់ចត់ជាមួយនឹងសកម្មភាពសំខាន់ៗផ្សេងទៀតដើម្បីធានាបាននូវប្រតិបត្តិការអាជីវកម្មប្រព្រឹត្តទៅដោយរលូន។ កម្មវិធីពិសេសដែលបង្កើតឡើងដើម្បីការពារដល់អតិថិជនដែលរងផលប៉ះពាល់ដោយ កូវីដ ១៩ ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ស្របទៅតាមការណែនាំពី ធនាគារជាតិនៃកម្ពុជា ។

សម្រាប់ប្រតិបត្តិការអាជីវកម្មក្នុងត្រីមាសទី ១ ទោះបីជាមានផលប៉ះពាល់ពី កូវីដ ១៩ យើងនៅតែអាចរីកចម្រើនបានយ៉ាងល្អក្នុងរយៈពេល ២ ខែដំបូង ខណៈពេលមានការធ្លាក់ចុះនៅខែ មីនា ដោយសារស្ថានភាពអាជីវកម្មនៅក្នុងប្រទេសកម្ពុជាទាំងមូលត្រូវបានប្រែប្រួល និងមួយចំនួនទៀតត្រូវផ្អាកដំណើរការ។
គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ហត្ថាកសិករ លីមីតធីត មានផលបត្រឥណទានសរុប ចំនួន ១ ១០៤ លានដុល្លារអាមេរិក ដែលបានកើនឡើង ៥ ភាគរយ ធៀបទៅនឹងត្រីមាសមុន។ យើងបានបន្តបម្រើសេវាយ៉ាងល្អប្រសើរទៅកាន់អតិថិជនឯកត្តជន និងអតិថិជនប្រភេទអាជីវកម្មជាមួយនឹងបណ្តាញដ៏រឹងមាំរបស់យើងនៅទូទាំងប្រទេសដើម្បីលើកកម្ពស់ជីវភាព ក៏ដូចជាស្ថានភាពអាជីវកម្មរបស់ពួកគេ។ ឥណទានស្ថិតក្នុងកម្រិតហានិភ័យ (៣០ ថ្ងៃ) ត្រូវបានគ្រប់គ្រងយ៉ាងល្អដោយមានត្រឹមតែ ០,៤២%។ ប្រាក់បញ្ញើសន្សំសរុបមានចំនួន ៥៥៩ លានដុល្លារអាមេរិក ពោលគឺធ្លាក់ចុះបន្តិចពីត្រីមាសមុនដោយសារការផ្ទុះឡើងនៃជម្ងឺ។ លទ្ធផលអាជីវកម្មដូចបង្ហាញខាងលើ បានបញ្ជាក់កាន់តែច្បាស់ពីស្ថិរភាពអាជីវកម្មរបស់ ហត្ថាកសិករ លីមីតធីត នៅលើទីផ្សារ។ ក្រោមការបំពេញការងារយ៉ាងយកចិត្តទុកដាក់ពីបុគ្គលិកដែលប្រកបដោយវិជ្ជាជីវៈ និងសមត្ថភាពគ្រប់គ្រាន់ចំនួន ៤ ៦៥៧ នាក់ ដើម្បីធានាថាអាជីវកម្មរបស់យើងនៅតែបន្តរីកចម្រើន។

ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់ និយ័តករ អតិថិជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រ និងជឿជាក់លើស្ថាប័នរបស់យើង។ នៅពេលខាងមុខបន្តទៅទៀតក្នុងឆ្នាំ ២០២០ នេះ យើងប្តេជ្ញាពង្រឹង ហត្ថាកសិករ លីមីតធីត លើគ្រប់វិស័យទាំងអស់ ក៏ដូចជាចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ ១៩ ដើម្បីសុខុមាលភាពរួមរបស់អតិថិជន និងប្រទេសកម្ពុជាយើងទាំងមូលផងដែរ។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២០
ហត្ថលេខា និង ត្រា

លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្ដីថ្លែងរបស់ប្រធានអគ្គនាយក

ឆ្លើយតបទៅនឹងការរីករាលដាលវីរុសកូរ៉ូណាថ្មី COVID-19 លើសកលលោក ជាពិសេសនៅក្នុងប្រទេសកម្ពុជា ហត្ថាកសិករ លីមីតធីត បានចូលរួមកំណារពារការរីករាលដាលនៃ វីរុសកូរ៉ូណាថ្មី COVID-19 ដូចខាងក្រោម៖

១- ណែនាំបុគ្គលិកឲ្យលាងសំអាតដៃ សំអាតការិយាល័យជាប្រចាំ រក្សាគំលាតសមរម្យក្នុងការទំនាក់ទំនងគ្នា។

២- បានដាក់ចេញនូវវិធានការឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃបន្ទាប់ពីសាមីបុគ្គលិក ឬសមាជិកក្រុមគ្រួសារត្រឡប់ពីក្រៅប្រទេសវិញ។

៣- ផ្ដល់ជូនទឹកលាងដៃសម្លាប់មេរោគឥតគិតថ្លៃដល់បុគ្គលិក និងអតិថិជនគ្រប់ពេលវេលា។

៤- ណែនាំឲ្យមានការត្រូវពិនិត្យសីតុណ្ហភាពបុគ្គលិក និងអតិថិជនទាំងអស់ នៅតាមការិយាល័យនីមួយៗ។

៥- ផ្អាកការបណ្ដុះបណ្ដាល ក្នុងថ្នាក់ ដោយត្រូវជំនួសវិញដោយការបណ្ដុះបណ្ដាលតាមអនឡាញ។

៦- បានបង្ហាញពីរបៀបការពារ ការឆ្លងនៃ កូវីដ១៩ ដល់អតិថិជន និងបុគ្គលិក តាមរយៈបណ្ដាញសង្គមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត។

បើទោះបីមានផលប៉ះពាល់ជាអវិជ្ជមានពី វីរុសកូរ៉ូណាថ្មី COVID-19 ក៏ហត្ថាកសិករ លីមីតធីត នៅតែឈរជើងយ៉ាងរឹងមាំនៅលើទីផ្សារហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា ដោយរក្សាប្រាក់ចំណេញបានយ៉ាងល្អគិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០២០ ។

លោកប្រធានអគ្គនាយក បានមានប្រសាសថា " ទោះបីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានទទួលនូវលទ្ធផលគួរជាទីពេញចិត្តក្នុងត្រីមាសទី១ ឆ្នាំ២០២០ ដែលវាបានឆ្លុះបញ្ចាំងពីផលប័ត្រឥណទាន មានតុល្យភាព និងការគ្រប់គ្រងហានិភ័យ ប្រកបដោយការប្រយ័ត្នយ៉ាងច្បាស់លាស់។

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ហត្ថាកសិករ លីមីតធីត ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេទី២ នៅប្រទេសកម្ពុជាសម្រាប់ទ្រព្យសកម្ម ប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ខ្លួន ព្រមទាំងម្ចាស់ភាគហ៊ុនជាធនាគារ Ayudhya ឈានមុខគេមួយនៅក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG ហេតុនេះធ្វើឲ្យហត្ថាកសិករ លីមីតធីត បានត្រៀមខ្លួនរួចជាស្រេច ទាំងធនធានមនុស្ស ទាំងដើមទុន និងបច្ចេកវិទ្យាព័ត៌មាន ក្នុងការក្លាយខ្លួនទៅជាធនាគារពាណិជ្ជ ដើម្បីបម្រើសេវាកម្ម និង ផលិតផលហិរញ្ញវត្ថុប្រកបដោយភាពស្មោះត្រង់ សាមញ្ញ និងមានវិជ្ជាជីវៈ ជាមួយនឹងទស្សនវិស័យឌីជីថលកាន់តែទំនើបដល់អតិថិជន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលបានប្ដេជ្ញាចិត្តធ្វើឱ្យសម្រេចសមិទ្ធផលដ៏អស្ចារ្យនេះ ទោះបីមានផលប៉ះពាល់ពីជំងឺកូវីដ-១៩ក៏ដោយ។ ខ្ញុំសូមកោតសរសើរ និងដឹងគុណចំពោះទំនុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូអាជីវកម្ម និងសាធារណជន ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថា នឹងផ្ដល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដាខ្ពស់បំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២០
ហត្ថលេខា



លោកឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iiii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ v

ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ក.លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ខ-រចនាសម្ព័ន្ធចំណូល ........ ៣

ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៤

ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៥

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៥

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៥

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៥

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៥

ង-ផលប៉ះពាល់នៃអតិផរណា ........ ៦

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៦

# ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហត្ថាកសិករ លីមីតធីត |
| ឈ្មោះជាអក្សរឡាតាំង | Hattha Kaksekar Limited |
| អក្សរកូដ | HKL |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hkl.com.kh |
| អ៊ីម៉ែល | info@hkl.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ម.ហ ០២-១២/០៦/១១/០១ ចេញដោយ: ធនាគារជាតិនៃកម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងHKLដោយ | លោក ហួត អៀងតុង |

ខ- លក្ខណៈនៃធុរកិច្ច

ហត្ថាកសិករ លីមីតធីត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំធំមួយ ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករ លីមីតធីត បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំងនៅទូទាំងប្រទេស។ គិតត្រឹមខែមីនា ឆ្នាំ ២០២០ សមតុល្យប្រាក់បញ្ញើសន្សំ របស់ហត្ថាកសិករ លីមីតធីត មានចំនួនជាង ៥៥៩ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជន ប្រាក់បញ្ញើសន្សំជាង ២៦៣ ៨២១នាក់ និងផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ១ ១០៤ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៧២ ៤៦៤នាក់។ បច្ចុប្បន្ន ហត្ថាកសិករ លីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារ Krungsri ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោម សម្ព័ន្ធហិរញ្ញវត្ថុ ធំជាងគេលើសកលលោក។

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

បើទោះបីជាកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជម្ងឺ**កូវីដ ១៩** យ៉ាងនេះក្ដី ហត្ថាកសិករ នៅតែបន្តប្រតិបត្តិការរបស់ខ្លួនយ៉ាងរឹងមាំ និងប្រកបដោយទំនុកចិត្តពីអតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធរបស់ខ្លួន។ ជាលទ្ធផលនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ប្រាក់កម្ចី ៥០ លានដុល្លារអាមេរិកជាមួយ ហត្ថាកសិករ លីមីតធីត ដើម្បីផ្ដល់មូលនិធិគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យមនៅតាមជនបទក្នុងប្រទេស។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ នាខែមីនា ឆ្នាំ២០២០ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៦៩ ៩០៧ | ១៧២ ៤៦៤ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ០៧២ ៩៥៣ | ១ ១០៣ ៥០៩ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៦០ ៨៤១ | ២៦៣ ៨២១ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៦៤១ ៩១៥ | ៥៥៨ ៦៣២ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៤៧ ២៤៣ | ៥២ ៨៦៨ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៨ ២០៤ | ៨ ៤៨៦ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ៨១ ៥៩៤ | ៩៤ ៦៩០ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ១ ០០២ ៥១៤ | ១ ៦៥៥ ២៣៩ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៣៩ | ១៣៧ |
| ចំនួនបុគ្គលិក | ៤ ៩៧៧ | ៤ ៦៥៧ |

ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ ២០២០ | | ត្រីមាសទី១ ឆ្នាំ ២០១៩ | | ត្រីមាសទី១ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៧៣ ៤៧៣ | ៩៦,៦ | ១២៧ ២០១ | ៩៥,៨ | ១០១ ៩៨១ | ៩៧,០ |
| ២ | ចំណូលផ្សេងៗ | ៦ ១២២ | ៣,៤ | ៥ ៥៨៦ | ៤,២ | ៣ ១៩៧ | ៣,០ |
| ចំណូលសរុប | | ១៧៩ ៥៩៥ | | ១៣២ ៧៨៧ | | ១០៥ ១៧៨ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនកររងករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

# ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ហត្ថាកសិករ លីមីតធីត ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ហត្ថាកសិករ លីមីតធីត ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់-ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ហត្ថាកសិករ លីមីតធីតតែប៉ុណ្ណោះ ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ការវិភាគចំណូល

ហត្ថាកសិករ លីមីតធីតមានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរ-ប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ហត្ថាកសិករ លីមីតធីតដែលមានរហូតដល់ ៩៦,៦% នៃចំណូលសរុប។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ នេះ គណៈគ្រប់គ្រងយល់ថា ហត្ថាកសិករ លីមីតធីត ការរីករាលដាលនៃ កូវីដ១៩ បានចាប់ផ្តើមមានផលប៉ះពាល់ជាអវិជ្ជមានដល់អាជីវកម្មជាពិសេសគឺ គុណភាពឥណទាន។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩នេះ គណៈគ្រប់គ្រងយល់ថា ហត្ថាកសិករ លីមីតធីត ពុំមានធាតុដែលជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ហត្ថាកសិករ លីមីតធីត បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង- ផលប៉ះពាល់នៃអតិផរណា**

ហត្ថាកសិករ លីមីតធីតមិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល**

នៅត្រីមាសទី ១ ក្នុងឆ្នាំ២០២០ ពេលដែលមានការរីករាលដាលនៃវីរុស កូវីដ១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើម និងអនុវត្តនូវវិធានការសំខាន់ៗជាច្រើនដើម្បីធានាអោយបាននូវកំណើន និងស្ថេរភាពសេដ្ឋកិច្ចជាតិ។ យើងសង្កេតឃើញថា មានក្រសួងពាក់ព័ន្ធ និងអាជ្ញាធរជាតិជាច្រើនបានចាត់វិធានការរបស់ខ្លួនដើម្បីប្រឆាំងការរីករាលដាលនៃកូវីដ១៩ និងដើម្បីធានានូវស្ថេរភាពសេដ្ឋកិច្ច រួមបញ្ចូលទាំងធនាគារជាតិនៃកម្ពុជាផងដែរ។ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការរូបិយវត្ថុមួយចំនួន ដូចខាងក្រោម ៖

- **គោលនយោបាយរូបិយវត្ថុទី ១៖** ដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃវីរុសកូវីដ ១៩ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការណ៍រូបិយប័ណ្ណមួយចំនួនដូចជា
  - លើកទឹកចិត្តដល់សមាជិកសមាគម ឲ្យបន្តផ្តល់ឥណទានដល់វិស័យអាទិភាព ជាពិសេសចំពោះអាជីវកម្មផ្នែកសណ្ឋាគារ ផ្ទះសំណាក់ ទេសចរណ៍ សំណង់ វាយនភណ្ឌកាត់ដេរ និងផលិតស្បែងជើង ដើម្បីធានានិរន្តរភាពអាជីវកម្មទាំងនោះ។
  - សមាជិកសមាគម គម្បីរក្សាភាពទន់ភ្លន់ និងពិនិត្យតាមលទ្ធភាពជាក់ស្តែងក្នុងការដោះស្រាយបំណុលយឺតយ៉ាវដែលបណ្តាលមកពីផលប៉ះពាល់នៃវីរុសកូវីដ ១៩ ។
  - សមាជិកសមាគម ត្រូវបន្តតាមដាន និងដាក់ចេញវិធានការ ការពារការរីករាលដាលវីរុសកូវីដ ១៩ ទៅលើបុគ្គលិក និងអតិថិជន ដើម្បីធានាឱ្យបាននិរន្តរភាពប្រតិបត្តិការ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាប្រក្រតី ។
- **គោលនយោបាយរូបិយវត្ថុ ទី ២៖** លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានចេញគោលនយោបាយរូបិយវត្ថុជាលើកទី ២ ដែលអាចធ្វើស្ថាប័នហិរញ្ញវត្ថុមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបន្តផ្តល់ជូនអតិថិជននៅក្នុងអំឡុងពេលការរីករាយដាលវីរុសកូវីដ ១៩។ គោលនយោបាយទាំងនោះ រួមមាន៖
  - ពន្យាពេលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន (CCB) ត្រឹម ៥0%
  - កាត់បន្ថយអត្រាការប្រាក់អប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ចំនួន 0,៥% ចំពោះគ្រប់ឥណប្រតិទាន
  - កាត់បន្ថយអត្រាការប្រាក់លើមូលបត្រអាចជួញដូរបាន (NCD) ចារឹកជារៀលនិងដុល្លារអាមេរិក ក្នុងកម្រិតសមស្រប
  - កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ពី ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណមកត្រឹម ៧% ទាំងចំពោះប្រាក់រៀលនិងរូបិយប័ណ្ណ ក្នុងរយៈពេល ៦ខែ ចាប់ពីខែមេសា ឆ្នាំ២០២០ និង
  - កាត់បន្ថយកម្រិតអនុបាតក្របខ័ណ្ឌសន្ទនីយភាព (LCR) ក្នុងកម្រិតសមស្រប តាមការចាំបាច់។

- **គោលនយោបាយរូបិយវត្ថុ ទី ៣៖** ក្នុងគោលបំណងរក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ ១៩ ជាពិសេសដើម្បីសម្រាលបន្ទុកដល់អ្នកខ្ចីប្រាក់ដែលកំពុងប្រឈមនិងការធ្លាក់ចុះនៃប្រាក់ចំណូលចម្បង និងមានការលំបាកក្នុងការទូទាត់សង **ធនាគារ** ជាតិនៃកម្ពុជា សម្រេចដាក់ឲ្យអនុវត្តនូវសារាចរណែនាំនេះ សំដៅធានាការរៀបចំឥណទានឡើងវិញដោយ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ធនាគារជាតិនៃកម្ពុជា តម្រូវឲ្យគ្រឹះស្ថានយកចិត្តទុកដាក់ជាមួយអតិថិជនដែលរងផលប៉ះពាល់ជាក់ស្តែង និងអនុញ្ញាតឲ្យរៀបចំឥណទានឡើងវិញ ចំពោះវិស័យអាទិភាពដូចខាងក្រោម៖

- ទេសចរណ៍ (សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន ដោយរាប់បញ្ចូលទាំងចំណីអាហារ ភេសជ្ជៈ និងសេវាកម្មគាំទ្រផ្សេងៗ)
- កាត់ដេរ (ដោយរាប់បញ្ចូលទាំងនិយោជិក)
- សំណង់ (ចំពោះតែឥណទានសាងសង់ផ្ទះ/ហាងដំបូង និងឥណទានទិញផ្ទះដំបូង) និង
- ការដឹកជញ្ជូន (ជាពិសេសអ្នកបើកបរតាក់ស៊ី និងរ៉ឺម៉កកង់បី) និងឡជីស្ទិក៕

## ហត្ថលេខារបស់អភិបាលហត្ថាកសិករ លីមីតធីត

កាលបរិច្ឆេទ៖ ១៥ ខែ មិថុនា ឆ្នាំ២០២០
បានអាន និងឯកភាព

លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ១៥ ខែ មិថុនា ឆ្នាំ២០២០
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

Subsidiary of krungsri bank

A member of MUFG, a global financial group